ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិបណ្តុះបណ្តាល
(NTB)

# កំណត់ហេតុប្រជុំ
# គណៈកម្មាធិការជាតិបណ្តុះបណ្តាល

ឆ្នាំពីរពាន់ប្រាំមួយ ខែមិនា ថ្ងៃទីមួយ វេលាម៉ោងប្រាំបួនព្រឹក នៅទីស្តីការគណៈរដ្ឋមន្ត្រី មានបើកអង្គប្រជុំគណៈកម្មាធិការជាតិបណ្តុះបណ្តាល (NTB) ក្រោមអធិបតីភាព ឯកឧត្តម **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងជាប្រធានគណៈកម្មាធិការជាតិបណ្តុះបណ្តាល (NTB)។

**សមាសភាពអញ្ជើញចូលរួម:**

-សមាជិកគណៈកម្មាធិការជាតិបណ្តុះបណ្តាលចំនួន ៣២ រូប អវត្តមាន ០៥ រូប

-លេខាធិការចំនួន ០៦ រូប

**របៀបវារៈនៃអង្គប្រជុំមាន :**

១-ប្រកាសបើកអង្គប្រជុំដោយឯកឧត្តម **សុខ អាន** ប្រធានគណៈកម្មាធិការជាតិបណ្តុះបណ្តាល (NTB)

២-របាយការណ៍របស់ឯកឧត្តម **ពេជ សោភ័ន** រដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងជាអនុប្រធានគណៈកម្មាការជាតិបណ្តុះបណ្តាល

៣-ការជ្រើសរើសគណៈកម្មការប្រតិបត្តិ EC

៤-ការអនុម័តផែនការទិសដៅការងារខាងមុខ

៥-បញ្ហាផ្សេងៗ។

**របៀបវារៈទី១ :**

ឯកឧត្តមប្រធានអង្គប្រជុំ បានថ្លែងអំណរគុណ និងស្វាគមន៍យ៉ាងកក់ក្តៅបំផុតចំពោះសមាជិក សមាជិកានៃអង្គប្រជុំ ដែលបានអញ្ជើញចូលរួមតាមការអញ្ជើញ ទោះបីមានការមមាញឹកខ្លាំងយ៉ាងណាក៏ដោយ ហើយនេះជាការប្រជុំលើកទី១បន្ទាប់ពីគណៈកម្មាធិការនេះបានរៀបចំកែសំរួលឡើងវិញ។ បន្ទាប់មកឯកឧត្តមប្រធានក៏បានអនុញ្ញាតជូនឯកឧត្តម **ពេជ សោភ័ន** រដ្ឋលេខាធិការនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងជាអនុប្រធានគណៈកម្មាធិការជាតិបណ្តុះបណ្តាលឡើងរាយការណ៍ ដើម្បីជំរាបជូនពីសកម្មភាព NTB កន្លងមក និងការងារដែលត្រូវអនុវត្តបន្តទៅថ្ងៃអនាគត។

**របៀបវារៈទី២ :**

✪បន្ទាប់ពីបានការអនុញ្ញាតពីឯកឧត្តមប្រធានអង្គប្រជុំរួចមកឯកឧត្តម **ពេជ សោភ័ន** បានមានប្រសាសន៍លើកឡើងអំពីចំណុចធំៗទាំង៤ ដែលមាននៅក្នុងរបាយការណ៍ហើយពាក់ពន្ធ័ទៅនឹងការងារដែលបានអនុវត្តកន្លងមក និងទិសដៅការងារសំរាប់ទៅថ្ងៃអនាគត :

-ប្រវត្តិរបស់ NTB (តើហេតុអ្វីបានជាមាន NTB?)

-មូលនិធិជាតិបណ្តុះបណ្តាល NTF

-សកម្មភាពការងារកន្លងមក

-ទិសដៅការងារទៅថ្ងៃអនាគត

***១-មូលហេតុបង្កើត NTB***

-ប្រពន្ធ័អប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ (TVET) មានលក្ខណៈរាយប៉ាយដាច់ដោយឡែកពីគ្នា នៅតាមក្រសួងផ្សេងៗ ហើយមាននយោបាយផ្សេងៗពីគ្នា ដែលធ្វើអោយមានការលំបាកដល់ការជួយរបស់អ្នកផ្តល់ជំនួយ ហើយមួយផ្នែកទៀតបានធ្វើអោយមានការខ្ជះខ្ជាយធនធាន (ក្រសួងខ្លះមានអគារតែអត់មានដំណើរការ ក្រសួងខ្លះត្រូវការបណ្តុះបណ្តាលតែគ្មានអគារ គ្មានគ្រូ)។ កម្មវិធី និងកំរិតបណ្តុះបណ្តាលមានតិច មិនទទំទួន់ មិនឆ្លើយតបនឹងទីផ្សារ សិស្សមួយចំនួនរៀនចប់ចេញទៅធ្វើការតែពេលចង់ត្រឡប់មកបន្តការសិក្សាវិញមិនអាចចូលបាន គ្មានថវិកាគ្រប់គ្រាន់សំរាប់ការបណ្តុះបណ្តាលប្រកបដោយគុណភាព។ មូលហេតុទាំងអស់នេះហើយដែលជាកត្តាធ្វើអោយអត្រាសិស្សចូលរៀនផ្នែក TVET នៅមានកំរិតទាប ។

-គោលដៅសំខាន់របស់ TVET គឺបណ្តុះបណ្តាលក្រុមជនដែលងាយរងគ្រោះក្នុងសង្គម ប៉ុន្តែពេលនេះ TVET មានមុខសញ្ញាមួយទៀត គឺសិស្សដែលបោះបង់ចោលការសិក្សានៅចំណោះទូទៅ

-ដោយជួបប្រទះបញ្ហាទាំងនេះ នៅឆ្នាំ ១៩៩៤ ADB បានបញ្ជូន Team មួយមកសិក្សាស្រាវជ្រាវហើយបានបង្កើត NTB ឡើងដើម្បីដោះស្រាយបញ្ហាលំបាកៗមួយចំនួន ដែលមាននៅក្នុង TVET និងសំដៅបង្កើតនូវវប្បធម៌ TVET មួយនៅកម្ពុជា។

- NTB ត្រូវបានបង្កើតឡើងនៅថ្ងៃទី ២៨ ខែវិច្ឆិកា ឆ្នាំ ១៩៩៦ ដែលជាអង្គការស្ម័គ្រចិត្តរៀបចំឡើងក្រោមគំរោង ADB ដោយមានថវិកាគាំទ្រពីគំរោង TA របស់ ADB ហើយមានការចូលរួមពីផ្នែក សាធារណៈ ឯកជន អង្គការអន្តរជាតិ និងអង្គការក្រៅរដ្ឋាភិបាល។

-នៅថ្ងៃទី ១១ ខែមិនា ឆ្នាំ ១៩៩៨ NTB បានក្លាយជាអង្គការចាត់តាំងជាតិមួយតាមរយៈអនុក្រឹត្យលេខ ១៨អនក្រ.បក

**ឯកឧត្តមបានបន្តទៀតថា:** ការអនុវត្តកន្លងមកបានបង្ហាញអោយឃើញថា NTB មានចំណុចខ្សោយមួយចំនួនគឺ:

- NTBគ្មានសិទ្ធិអំណាច (ប្រធាន NTB មានកំរិតនៅទាប ត្រឹមរដ្ឋលេខាធិការ)

- NTB គ្មានថវិកាសំរាប់ដំណើរការ

-នាឆ្នាំ ២០០២ អង្គការ ILO សហការជាមួយក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា បានបើកសិក្ខាសាលាមួយនៅថ្ងៃទី ១៩ ដល់ ថ្ងៃទី ២០ ខែវិច្ឆិកា ឆ្នាំ ២០០២ នៅសណ្ឋាគារសាន់វេហើយបានលើកឡើងនូវអនុសាសន៍ពីរគឺ ពង្រឹង NTB ទាំងផ្នែកហិរញ្ញវត្ថុ និងសិទ្ធិអំណាច ហើយ TVET ត្រូវស្ថិតនៅក្រោមការគ្រប់គ្រងរបស់ស្ថាប័នតែមួយ ។

-ដើម្បីដោះស្រាយបញ្ហាខាងលើ រាជរដ្ឋាភិបាលនៅក្នុងអាណត្តិទី៣នេះ បានបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្នុងទិសដៅដើម្បីប្រមូលការទទួលខុសត្រូវក្រោមក្រសួងតែមួយ ។ ប៉ុន្តែការអប់រំគឺ បណ្តុះបណ្តាលវិជ្ជាជីវៈគឺ មិនអាចស្ថាប័នមួយធ្វើបានទេ ដូច្នេះត្រូវគ្រប់គ្នាធ្វើទាំងអស់គ្នា គ្រាន់តែស្ថាប័នមួយជាអ្នករៀបចំគោលនយោបាយសំរបសំរួលការងារនេះ ។

-បានធ្វើកំណែទំរង់ NTB តាមអនុក្រឹតលេខ ៦៥អនក្រ-បក ចុះថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ២០០៥ ដែល មានឯកឧត្តមឧបនាយករដ្ឋមន្ត្រីជាប្រធាន ។

-សមាសភាព NTB មាន:

- -រាជរដ្ឋាភិបាលចំនួន ១៩ រូប ។
- -និយោជកចំនួន ៦ រូប
- -និយោជិតចំនួន ២ រូប
- -គ្រឹះស្ថានបណ្តុះបណ្តាល ៣ រូប
- - NGO / IOs ចំនួន៣ រូប ។

-NTB ត្រូវប្រជុំ២ដង រឺលើសពីនេះក្នុងមួយឆ្នាំ តាមការកោះអញ្ជើញរបស់ប្រធាន ហើយក្នុងដំណើរការនៃការអនុវត្តការងារចន្លោះពេលប្រជុំនីមួយៗ ត្រូវមានគណៈកម្មការប្រតិបត្តិ (EC) មួយសំរាប់ដោះស្រាយបញ្ហា និងមានភារកិច្ចគ្រប់គ្រងមូលនិធិជាតិបណ្តុះបណ្តាល (NTF) ផង ។

-សមាសភាព EC មានចំនួន ១០ រូប

| | |
|---|---|
| -ប្រធាន NTB | ប្រធាន |
| -តំណាងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | អនុប្រធាន |
| -តំណាង ២ រូបរបស់ក្រសួង រឺស្ថាប័នរាជរដ្ឋាភិបាល | សមាជិក |
| -តំណាង ២ រូបរបស់និយោជក | សមាជិក |
| -តំណាង ១ រូបរបស់និយោជិក | សមាជិក |
| -តំណាង ១ រូបរបស់គ្រឹះស្ថានបណ្តុះបណ្តាល | សមាជិក |
| -តំណាង ១ រូបរបស់ NGOs / IOs | សមាជិក |
| -នាយកប្រតិបត្តិ NTB | លេខាអចិន្ត្រៃយ៍ |

-នៅតាមខេត្ត-ក្រុង ត្រូវបង្កើតគណៈកម្មាធិការខេត្ត-ក្រុងបណ្តុះបណ្តាល PTB ដែលមានសមាសភាពដូចថ្នាក់ជាតិដែរ ។

**ភារកិច្ចរបស់ NTB**

- NTB ត្រូវរៀបចំគោលនយោបាយ និងផែនការជាតិសំរាប់ TVET

-សំរបសំរួលតំរង់ទិសការងារ TVET ដើម្បីឆ្លើយតបទៅនឹងតំរូវការនៃការអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិក្នុងពេលបច្ចុប្បន្ន និងទៅអនាគត

-កែតំរង់ និងអភិវឌ្ឍន៍ TVET អោយក្លាយទៅជាប្រព័ន្ធមួយដែល :

-មានគុណភាព និងប្រសិទ្ធភាពខ្ពស់

-ផ្សារភ្ជាប់ទៅនឹងអាទិភាពនៃការអភិវឌ្ឍន៍ជាតិ

-ឆ្លើយតបទៅនឹងតំរូវការឧស្សាហកម្ម ពាណិជ្ជកម្ម កសិកម្ម និងសេវាកម្ម

-មានទំនាក់ទំនងល្អរវាងកន្លែងការងារ និងគ្រឹះស្ថានបណ្តុះបណ្តាល

☞ ប្រព័ន្ធ TVET មានគោលដៅធំ៣:

-បំរើ រឺឆ្លើយតបទៅនឹងសំណូមពរសហគ្រាស

-ឆ្លើយតបទៅនឹងសេចក្តីត្រូវការរបស់សហគមន៍

-ឆ្លើយតបទៅនឹងសំណូមពររបស់បុគ្គលម្នាក់ៗដើម្បីអោយគេបង្កើនប្រាក់ចំណូលរបស់គេ

☞TVET ត្រូវផ្សារភ្ជាប់ជាមួយកន្លែងការដ្ឋាន និងទីផ្សារការងារ

**ចំណែកឯ EC មានភារៈកិច្ច**

-គ្រប់គ្រងមូលនិធិជាតិបណ្តុះបណ្តាល NTF

-រៀបចំកម្មវិធី និងរបៀបវារៈ ប្រជុំរបស់ NTB

-លើកសំណើដែលពាក់ពន្ធ័ការងារ TVET ជូន NTB ពិនិត្យសំរេច

-ដោះស្រាយរាល់ការងារក្នុងចន្លោះពេលប្រជុំ NTB ។

***២-មូលនិធិជាតិបណ្តុះបណ្តាល (NTF)***

NTF ត្រូវបានបង្កើតឡើងក្នុងការអនុវត្តគោលនយោបាយកាត់បន្ថយភាពក្រីក្ររបស់រដ្ឋាភិបាល និងដើម្បីលើកកំពស់គុណភាពបណ្តុះបណ្តាលហើយដែលមានសមាសភាគ ៣ :

១-មូលនិធិផ្តល់អោយការបណ្តុះបណ្តាល (Training Grant Fund –TGF) ផ្តល់ជូនសំរាប់ធ្វើការបណ្តុះបណ្តាលដោយគ្មានសំណង អនុវត្តបាន ៨ ជំហាន បណ្តុះបណ្តាលបាន ១៣០៨៤នាក់ ដែលក្នុងនោះមានស្ត្រីចំនួន ៦៩៧៦នាក់ ស្មើនឹង៥០% ជំនាញបណ្តុះបណ្តាលបាន ៥៣មុខ នៅ ២៤ខេត្ត-ក្រុង ហើយអ្នកដែលបានការងារធ្វើមាន ៨៦៦៤នាក់ (៦៦%) ស្រី ៤៥២៥នាក់ (៧៥%) ផ្នែកនេះបានចប់ជាស្ថាពរក្នុងឆ្នាំ ២០០១ ហើយបានបន្តអនុវត្តដោយថវិកាកម្មវិធីសកម្មភាពជាអាទិភាព PAPចាប់ពីឆ្នាំ ២០០២ មកដល់បច្ចុប្បន្ន។

២-មូលនិធិជំនួយវិនិយោគសំរាប់ជំនាញបង្កើតថ្មី ( Innovative Skills Investment Assistance Fund- ISIAF) កន្លងមកយើងបានផ្តល់ប្រាក់អោយខ្ចី ដោយមានអង្គការចំនួន ៥ បានខ្ចីថវិកានេះ:

-សមាគមនារីដើម្បីសន្តិភាព និងអភិវឌ្ឍន៍

-សាលាបង្រៀន PTS

-សមាគមអភិវឌ្ឍន៍សេដ្ឋកិច្ចបែបគ្រួសារ

-សមាគមអភិវឌ្ឍន៍កសិកម្ម

-សមាគមបង្កាត់ពូជគោបែបសប្បុរិមិត្ត

៣-មូលនិធិបង្កើតមុខរបរដោយខ្លួនឯង (Self Employment Generation Fund-SEGF) ផ្នែកនេះយើងបាន អោយតែសិក្ខាកាម ដែលបានទទួលការបណ្តុះបណ្តាលនៅក្រោមការបណ្តុះបណ្តាលរបស់ NTF ក្នុងនោះយើងអនុវត្តបាន ៧ជំហាន ១៥ ខេត្ត ក្រុង ដែលមានអ្នកខ្ចីចំនួន ៥៦៥៣នាក់ ( ស្រី ៣៦៤៥នាក់ ស្មើនឹង ៦៥%) ។

***៣-សកម្មភាពការងារកន្លងមក:***

-កំណែទំរង់ប្រពន្ធ័ TVET

-System Management (Macro and Micro levels)
-Demand-driven system (LMIS, TENA, ILU…)
-Modular-based (Time Based)
-Competency-based
-Trainee-center
-Recognition of Prior Learning (RPL)
-Decentralized Management ( Income Generation)
-National Occupational Skills Standards, Testing Accreditation and Certification
-Gender and Equal Opportunities (GEO)
-Levy- Grant system and sustainable operations of NTF
-Formulation and implementation of new TVET structure.

-ប្រព័ន្ធ ស្តង់ដា ធ្វើតេស្ត ទទួលស្គាល់ និងការបញ្ជាក់

-ផ្នែកស្តង់ដាសមត្ថភាព:

-សេចក្តីព្រាងក្របខណ្ឌគុណវឌ្ឍិជាតិ (National Qualification Framework)

-សេចក្តីព្រាងស្តង់ដាសមត្ថភាពបាន ៣៤ មុខរបរ ពីកំរិត១ ដល់កំរិត៤

-ផ្នែកការងារតេស្ត:

-គោលការណ៍ណែនាំស្តីពីការធ្វើតេស្តសមត្ថភាព

-កញ្ចប់តេស្តសមត្ថភាពចំនួន ៣៤មុខជំនាញ

-ការទទួលស្គាល់:

-លក្ខណៈវិនិច្ឆ័យសំរាប់ទទួលស្គាល់គ្រឹះស្ថាន TVET

-លក្ខណៈវិនិច្ឆ័យសំរាប់ទទួលស្គាល់វគ្គ-កម្មវិធី TVET

-លក្ខណៈវិនិច្ឆ័យសំរាប់ទទួលស្គាល់សមត្ថភាពមេប្រយោគតេស្តបញ្ជាក់សមត្ថភាព

-លក្ខណៈវិនិច្ឆ័យសំរាប់ទទួលស្គាល់មជ្ឈមណ្ឌលធ្វើតេស្តបញ្ជាក់សមត្ថភាព

***៤-ទិសដៅការងារទៅអនាគត:***

-សេចក្តីត្រូវការសំរាប់ការងារ និងមុខជំនាញបណ្តុះបណ្តាល

-គំរោង ESDP II ADB Loan 2122-CAM(SF)

✪ឯកឧត្តម **សុខ អាន** មានប្រសាសន៍ថា :

ចំពោះ Tableau ( General Structure of an Economy) ត្រង់ Industry និង Service មិនទាន់ស៊ីគ្នានឹងសភាពការណ៍បច្ចុប្បន្ន ហើយដែលមាន៤ ស្ថាប័នសំខាន់ៗដែលត្រូវសំរួលអោយស៊ីគ្នា:

-NTB

-ភូមិមួយ ផលិតផលមួយ

-សភាសិប្បកម្ម និងការអនុវត្តគោលនយោបាយ SME

-ទេសចរណ៍

គួរអង្គប្រជុំពិនិត្យកែសំរួល Tableau នេះអោយស៊ីនឹងសភាពការណ៍បច្ចុប្បន្នទាន់ពេលដែលយើងមាន Tableau ស្រាប់ ។

✪ឯកឧត្តម **ពេជ សោភ័ន** បានបន្តទៀតថា :

១-ចំពោះសេចក្តីត្រូវការសំរាប់ការងារ និងមុខជំនាញបណ្តុះបណ្តាល :

-ចំនួនការងារសរុបបានកើនឡើងពី ៣.៩៤ លាន ក្នុងឆ្នាំ ១៩៩៣ ឡើងដល់ ៦.៤០ លានក្នុងឆ្នាំ២០០២ ហើយគិតជាអត្រាកំណើន គឺត្រូវជា ៥.៥០%ក្នុងមួយឆ្នាំ

-អត្រាកំណើនការងារប្រចាំឆ្នាំសំរាប់វិស័យសំខាន់ៗ គឺ:

-កសិកម្ម ៣.៨០%

-ឧស្សាហកម្ម ២១.៣០%

-សេវាកម្ម ៧.៩០%

-ពិតមែនតែផ្នែកឧស្សាហកម្មបានកើនឡើងលឿនជាងគេ ២១.៣០% ប៉ុន្តែកំណើននេះនៅតែតូចណាស់ពីព្រោះវាគ្រាន់តែស្មើនឹង ១០.៥០% នៃចំនួនការងារសរុបប៉ុណ្ណោះ ហើយវាអាស្រ័យលើឧស្សាហកម្មមួយចំនួនតូច ពិសេសគឺឧស្សាហកម្មសំលៀកបំពាក់ ។

-ផ្នែកកសិកម្មនៅតែស្ថិតនៅជាប្រភពសំខាន់ជាងគេ សំរាប់ការងារពីព្រោះវាស្មើនឹង ៧០% នៃចំនួនការងារសរុប ។

-ក្នុងចំនួនកាងារទាំងអស់មានតែ ១២% ប៉ុណ្ណោះនៅទីក្រុង ឯចំនួន ៨៨%ទៀតគឺនៅជនបទ ។

-ក្នុងចំនួនការងារសរុបមាន:

-១.១០% ជាអ្នកវិជ្ជាជីវៈ

-១.៩០% ជាអ្នកបច្ចេកទេស

-៣.៣០% ជាករីម៉ាស៊ីន និងគ្រឿងចក្រ

-៧.៦០% ជាពាណិជ្ជករ និង សិប្បករ

-៦៧.៦០% ជាកសិករ និង អ្នកនេសាទ

-ទំរង់នៃកំលាំងពលកម្ម

-កំរិតនៃការអប់រំ និងជំនាញរបស់កំលាំងពលកម្មនៅទាប:

-០.៧០% ក្រោយឧត្តមសិក្សា

-១.២០% អ្នកបច្ចេកទេស/ឧត្តមសិក្សា

-៤.៥០% ថ្នាក់ទី១០-១២

-១៨.៤០% ថ្នាក់ទី៧-៩

-៧៥.២០% ថ្នាក់ទី៦ រឺទាបជាង

-ក្រុមយុវជនដែលមានអាយុ ១២-២១ឆ្នាំ មានចំនួនសរុប ៣.២៨លាននាក់នៅឆ្នាំ២០០២

-ក្នុងក្រុមយុវជនខាងលើមានតែ ០.៥៨លាននាក់ ស្មើនឹង ១៨% ប៉ុណ្ណោះនៅក្នុងសាលារៀន ចំណែកឯ ២.៧លាននាក់ ស្មើនឹង ៨២%ស្ថិតនៅក្រៅសាលារៀន

-ដូច្នេះការបន្ថែមថ្មីនៃកំលាំងពលកម្ម នឹងនៅតែមានកំរិតអប់រំ/ ជំនាញទាបជាបន្តទៀត។ អាស្រ័យហេតុនេះ យើងត្រូវតែមានប្រព័ន្ធសមស្របមួយដើម្បីដោះស្រាយបញ្ហានេះ។

-នេះគឺជាតួនាទី និងភារកិច្ច (បេសកកម្ម)ដែលប្រព័ន្ធអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈត្រូវប្រឈមមុខ។ លើសពីនេះទៅទៀត កំលាំងពលកម្មដែលមានកំរិតអប់រំ/ជំនាញទាប ដែលមាននៅលើទីផ្សារពលកម្មជាយូរមកហើយ ក៏ត្រូវបូកបញ្ចូលមកដើម្បីគិតគូរដោះស្រាយដែរ។

-យុទ្ធសាស្ត្រសំខាន់ៗ

-ផ្លាស់ប្តូរក្នុងទស្សនវិទ្យាមូលដ្ឋាន: ពីប្រព័ន្ធដែលផ្អែកលើលទ្ធភាពផ្គត់ផ្គង់ (Supply-driven) ទៅជាប្រព័ន្ធ ដែលផ្អែកលើតំរូវការ( Demand-Driven) ផ្អែកលើតំរូវការរបស់សហគមន៍ និងឧស្សាហកម្ម។

-ផ្លាស់ប្តូរក្នុងកម្មវិធី: ពីជំនាញទីក្រុង (Urban Skills) ទៅជាជំនាញសំរាប់ជនបទ (Rural Skills) នៅក្នុងគ្រាដំបូង។

-ផ្លាស់ប្តូរតួនាទីរបស់មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត (PTCs) : ពីការផ្តល់ការបណ្តុះបណ្តាលដោយផ្ទាល់ ទៅជាអ្នកគ្រប់គ្រង (Manager) អ្នកជួយគេអោយបានសំរេច (Enabler) អ្នកសំរបសំរួល (Coordinator) និងជាអ្នកត្រួតពិនិត្យគុណភាព ( Quality Controller)

-ក្រុមមុខសញ្ញាត្រូវទទួលផល: អាទិភាពសំរាប់អ្នកមានទីលំនៅជាប់នឹងឃុំក្របំផុតចំនួន ៤០%

-អ្នកទទួលផលរួមចំណែកក្នុងការចំណាយ

-ប្រពន្ធ័គ្រប់គ្រងលទ្ធផលផ្អែកលើការលើកទឹកចិត្ត

២-គំរោង ESDP II ADB Loan 2122 CAM (SF)

-គំរោងនេះមាន សមាសភាគ៣

-ការអភិវឌ្ឍន៍នៅមធ្យមសិក្សាបឋមភូមិ (Lower secondary Development)

-ការអភិវឌ្ឍន៍នៅមធ្យមសិក្សាទុតិយភូមិ (Upper secondary Development)

-ការបណ្តុះបណ្តាលជំនាញផ្អែកលើតំរូវការរបស់សហគមន៍ (Demand-Driven Community-Based Skills Training) (TVET)

-គោលបំណងទូទៅ: ដើម្បីចាប់ផ្តើមនូវដំណាក់កាលដំបូង នៃកម្មវិធីបណ្តុះបណ្តាលជំនាញផ្អែកលើតំរូវការរបស់សហគមន៍។

-ក្រុមគោលដៅ:

-យុវជនក្រៅសាលា

-យុវជន ដែលគ្មានការងារធ្វើ និងអ្នកដែលធ្វើការងារបានប្រាក់កំរៃតិច

-ក្រុមយុវជនដែលមានអាយុចន្លោះ ១៥-២១ឆ្នាំ ត្រូវបានផ្តល់អាទិភាព

-ស្ថិតនៅក្នុង ៤០% នៃឃុំដែលក្រជាងគេនៅក្នុងខេត្ត ៧។

ក-Commune Training voucher (4.2 millions US$) គាំទ្រ និងអនុវត្តដោយ NTF

-ក្នុង ESDP II នឹងអនុវត្តក្នុង ៧ ខេត្ត ដោយជ្រើសរើសយកឃុំដែលក្រជាងគេបំផុតចំនួន (៤០%) ដែលមាន ២១០ឃុំ ។

-ជំហានដំបូង និងចាប់ផ្តើមនៅខេត្តបាត់ដំបង និងកំពត

ខ-មូលនិធិសំរាប់កែលំអរ ឧបករណ៍សំភារៈបរិក្ខា (0.5 millions US$) បង្កើត Tool Bank និង Local community lifelong learning centers/institution.

កញ្ចប់ថវិកា (15,000US$ ) នឹងផ្តល់ជូនដល់មជ្ឈមណ្ឌលនៅតាមតំបន់ ដើម្បីទិញសំភារៈបរិក្ខាបំពាក់ក្នុងមជ្ឈមណ្ឌលរបស់ខ្លួន។

គ-ការកសាងសមត្ថភាពក្នុងប្រព័ន្ធ TVET

-ថ្នាក់ជាតិ

-ថ្នាក់ខេត្ត

-ថ្នាក់ឃុំ

ក្រោយពីបានការអនុញ្ញាតពីឯកឧត្តមប្រធានអង្គប្រជុំ ឯកឧត្តម **ពេជ សោភ័ន** បានបន្តទៅផ្នែកទី២នៃរបាយការណ៍ ទាក់ទងទៅនឹងផែនការជាតិសំរាប់អភិវឌ្ឍន៍វិស័យ TVET ដែលក្នុងនោះឯកឧត្តមបានលើកឡើងពី Challenge ទាំង៦ និង Policy ទាំង១៤ ដែលត្រូវអនុវត្តបន្ត។

✪ឯកឧត្តមសុខ អាន មានប្រសាសន៍លើកឡើងថា:

-យើងគួរបញ្ចូលអ្នកញៀនគ្រឿងញៀន ក្មេងហិតការ ដែលបានអប់រំអោយផ្តាច់ញៀនរួចហើយ អាចចូលមកទទួលការបណ្តុះបណ្តាលជំនាញក្នុងសាលារបស់យើង បើធ្វើយ៉ាងនេះបានវាជាការល្អ ព្រោះនេះជាកង្វល់មួយរបស់យើង។

-តាមបទឧទ្ទេសនាមនេះអ្វីដែលសំខាន់ ជាងគេគឺ Challenge ទាំង៦ និង Policyទាំង ១៤ ដែលត្រូវប្រកាន់យក។ បទឧទ្ទេសនាមនេះស៊ីជំរៅណាស់ ហើយមានលក្ខណៈជំនាញណាស់ ដូច្នេះសូមឯកឧត្តមអស់លោកជាសមាជិកទាំងអស់សុំមេត្តា បន្តការសិក្សារឿងនេះ ហើយធ្វើការកត់សំគាល់បើមានអ្វីបន្ថែម រឺកែប្រែ និងសំណូមពរផ្សេងៗ សុំផ្ញើមកឯកឧត្តម ពេជ សោភ័ន រឺក៏មកលេខាធិការ ដើម្បីកែសំរួល និងបូកសរុបបន្ថែម។

**របៀបវីរៈទី៣ :**

✪ឯកឧត្តម **ពេជ សោភ័ន** បានលើកឡើងអំពី :

សំណើជ្រើសរើស គណៈកម្មការប្រតិបត្តិ EC ចំនួន ១០រូបដែលមានសមាសភាពដូចខាងក្រោមនេះ :

| | | | |
|---|---|---|---|
| -ឯកឧត្តម | សុខ អាន | ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទីស្តីការគណៈរដ្ឋមន្ត្រី | ជាប្រធាន |
| -ឯកឧត្តម | ពេជ សោភ័ន | រដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | ជាអនុប្រធាន |
| -ឯកឧត្តម | ម៉ែន ហាន | រដ្ឋលេខាធិការក្រសួងផែនការ | ជាសមាជិក |
| -បណ្ឌិត | ហ៊ាន សាហ៊ីប | អគ្គលេខាធិការរងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ជាសមាជិក |
| -លោក | តាន់ មុនីវណ្ណ | អគ្គនាយករងក្រុមហ៊ុនម៉ុងរីទ្ធីគ្រុប តំណាងនិយោជក | ជាសមាជិក |
| -លោក | ខេង លូ | តំណាងវិស័យឧស្សាហកម្មកាត់ដេរ តំណាងនិយោជក | ជាសមាជិក |
| -លោក | ជួន មុំថុល | ប្រធានសហភាពសហព័ន្ធសហជីពជាតិកម្ពុជា តំណាងនិយោជិត | ជាសមាជិក |
| -ឯកឧត្តម | ប៊ុន ភារិន | នាយកវិទ្យាស្ថានជាតិពហុបច្ចេកទេសកម្ពុជា តំណាងអ្នកផ្តល់ការបណ្តុះបណ្តាល | ជាសមាជិក |
| -លោក | យក់ អៀង | តំណាង NGO | ជាសមាជិក |
| -ឯកឧត្តម | ឡៅ ហ៊ិម | អគ្គនាយកនៃអគ្គនាយកដ្ឋានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ នៃ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | ជានាយកប្រតិបត្តិ |

**របៀបវារៈទី៤ :**

✪ឯកឧត្តម **ពេជ សោភ័ន** បានបន្តទូវរបៀបវារៈចុងក្រោយលើការសុំអនុញ្ញាត ដើម្បីសំរេចពីអង្គប្រជុំលើការអនុវត្តការបណ្តុះបណ្តាលតាម Vouchers System ក្នុងខេត្តចំនួន ៧ រួមមាន បាត់ដំបង កំពង់ស្ពឺ កំពត សៀមរាប ស្ទឹងត្រែង ស្វាយរៀង និងតាកែវ ហើយជ្រើសរើសយកឃុំដែលក្រជាងគេចំនួន៤០% តែ ជាជំហានដំបូងយើងអនុវត្តនៅខេត្តបាត់ដំបង និងកំពតមុនគេ។

✪ឯកឧត្តម **សុខ អាន** បានលើកជាអនុសាសន៍ឡើងថា:

-ស្នើដាក់ខេត្តកំពង់ឆ្នាំងមួយផងព្រោះជាខេត្តដែលនៅកណ្តាលគេហើយក្រ

-ចំពោះខេត្តជាប់ព្រំដែនគួរអោយទៅឃុំណាដែលនៅជាប់នឹងព្រំដែន

-ស្នើរអង្គប្រជុំផ្ញើរឈ្មោះឃុំ ដែលសុំផ្លាស់ប្តូរ រឺមានយោបល់អ្វី មកលេខាធិការក្នុងរយៈពេល ១សប្តាហ៍ ដើម្បីធ្វើការពិចារណា

-ការងារ NTB ជាការងារយូរអង្វែង ដូច្នេះសុំអោយសមាជិកទាំងអស់ត្រូវសិក្សាស្វែងយល់លើឯកសារទាំងនេះ

-គួរមានយន្តការតូចមួយទៀតនៅក្នុង NTB ដើម្បីសិក្សាអំពីតំរូវការការងារព្រោះតាមការស្រាវជ្រាវបានលើកឡើងអំពីអ្នកដែលត្រូវការការងារធ្វើ ៣២ម៉ឺននាក់ ក្នុង១ឆ្នាំ នៅពេលដែលការងារមានតែ ៥ម៉ឺននាក់។

- NTB ជោគជ័យអាស្រ័យលើវិនិយោគចូលរួម បើគ្មាន NTB មានវិនិយោគក៏មិនល្អ តែបើមានវិនិយោគតិច មាន NTB ក៏មិនល្អដែរ មានវិនិយោគច្រើន ព្រមទាំងមាន NTB ទើបល្អ។

ជាទីបញ្ចប់អង្គប្រជុំបានឯកភាពលើចំណុចមួយចំនួនដូចខាងក្រោម:

-សមាសភាពទាំង ១០ រូប របស់គណៈកម្មការប្រតិបត្តិ EC

-ស្នើសុំប្តូរខេត្តណាមួយក្នុងចំណោមខេត្តទាំង ៧ ដែលបានលើកឡើងខាងដើម ទៅអោយខេត្តកំពង់ឆ្នាំង

-ឯកភាពដោយទុករយៈពេល១សប្តាហ៍ក្រោយពីប្រជុំសំរាប់សមាជិក NTB ពិនិត្យ និងផ្តល់យោបល់លើបញ្ហាប្រឈមទាំង ៦ចំណុច និងនយោបាយទាំង ១៤ ចំនុច សំរាប់ការអភិវឌ្ឍន៏វិស័យអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ

សុំអោយអង្គប្រជុំផ្ញើជាយោបល់មកលេខាធិការក្នុងរយៈពេល ១ សប្តាហ៍ បើមិនឃើញផ្ញើមកទេចាត់ទុកថា បានឯកភាពតាមឯកសារដែលបានដាក់ជូន។

អង្គប្រជុំបានចប់សព្វគ្រប់នៅវេលាម៉ោងដប់បីគត់នាថ្ងៃខែឆ្នាំដដែល ក្រោមបរិយាកាសស្និទ្ធស្នាល និងទទួលខុសត្រូវខ្ពស់។

លេខាកត់ត្រា

បានឃើញ និងឯកភាព

ប្រធានអង្គប្រជុំ